# នីតិវិធីឃុំខ្លួនបណ្ដោះអាសន្ន អនីតិជននៅកម្ពុជា

ការឃុំខ្លួនបណ្ដោះអាសន្ន គឺជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្ដី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ ដើម្បីធានាមិនឱ្យមាននូវអវត្តមានរបស់ជនជាប់ចោទនៅចំពោះមុខតុលាការ ក៏ដូចជាការបង្ការមិនឱ្យមានការរំខានដល់ដំណើរការនៃការស៊ើបអង្កេត ហើយអាចធ្វើឡើងបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ ឡើងទៅ។ (មាត្រា ២០៣ និង២០៤ ក្រមនីតិវិធីព្រហ្មទណ្ឌ)

## ការឃុំខ្លួនត្រូវតែជាជម្រើសចុងក្រោយ និងរយៈពេលខ្លី

## តើហេតុអ្វីត្រូវចាំបាច់ឃុំខ្លួន នៅពេលដែលមានបទល្មើស?

មូលហេតុនៃការឃុំខ្លួនបណ្ដាលមកពី៖

១. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតមានឡើងជាថ្មី។

២. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥. ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។

៦. ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស។

(មាត្រា ២០៥
ក្រមនីតិវិធីព្រហ្មទណ្ឌ )





## តើដំណាក់កាលសំខាន់ៗ របស់នីតិវិធីព្រហ្មទណ្ឌ រួមមានអ្វីខ្លះ?

ដំណាក់កាលសំខាន់ៗ នៅក្នុងនីតិវិធីព្រហ្មទណ្ឌរួមមាន៖

- ដំណាក់កាល នគរបាលយុត្តិធម៌
- ដំណាក់កាល អយ្យការ
- ដំណាក់កាល ការស៊ើបសួរ
- ដំណាក់កាល ជំនុំជម្រះ។



## តើអនីតិជនត្រូវបានឃុំខ្លួនក្នុងថេរវេលាប៉ុន្មាន នៃបទល្មើសដែលប្រព្រឹត្ត?

ក្នុងបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី៤ខែបានទេ កាលណាអនីតិជនមានអាយុតិចជាង ១៦ ឆ្នាំ និងមិនអាចលើសពី ៦ ខែ កាលណាអនីតិជនមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ ក្រោម ១៨ ឆ្នាំ ក្នុងបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ២ ខែ បានទេ កាលណាអនីតិជនមានអាយុតិចជាង ១៦ឆ្នាំ និងមិនអាចលើសពី ៤ ខែ កាលណាអនីតិជនមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ ក្រោម ១៨ ឆ្នាំ។ ឯអនីតិជនមានអាយុក្រោម ១៤ ឆ្នាំ មិនត្រូវឃុំខ្លួនបណ្ដោះអាសន្ននោះទេ។ (មាត្រា ២១២ ២១៣ និង២១៤ ក្រមនីតិវិធីព្រហ្មទណ្ឌ)

## តើការឃុំខ្លួនផ្ដល់ផលប៉ះពាល់អ្វីខ្លះដល់អនីតិជន?

ការឃុំខ្លួនទៅលើអនីតិជន អាចផ្ដល់នូវផលប៉ះពាល់ដូចជា៖

ផ្លូវកាយ៖ ងាយប្រឈមនឹងអំពើបៀតបៀន និងការរំលោភសិទ្ធនានា។

ផ្លូវអារម្មណ៍៖ ធ្លាក់ជាប់គំនិត និងផ្លូវអារម្មណ៍របស់ពួកគេ។

កិត្តិយស ៖ ទទួលរងការប្រមាថ ម៉ាក់ងាយ និងមិនឱ្យតម្លៃពីមជ្ឈដ្ឋានជុំវិញ។

ចំណេះដឹងនិងការលូតលាស់៖ បង្អាក់ និងប៉ះពាល់ដល់ការលូតលាស់នៃកុមារ។ (CHILDREN IN PRETRIAL DETENTION REPORT, 2018)



## តើស្ថាប័នពាក់ព័ន្ធណាខ្លះ អាចគាំពារអនីតិជនដែលទទួលរងភាពអយុត្តិធម៌?

អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍ

យូនីសេហ្វ ដើម្បីកុមារគ្រប់រូប

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ព្រមទាំងស្ថាប័នផ្សេងៗជាច្រើនទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា

### ឯកសារយោង៖


១. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

២. CHILDREN IN PRETRIAL DETENTION REPORT

៣. យូនីសេហ្វ កិច្ចការពារកុមារ | អង្គការយូនីសេហ្វ អង្គការយូនីសេហ្វ (unicef.org)


### រៀបរៀងដោយនិស្សិត៖


កញ្ញា ប៊ុន សុបុញ្ញតា កញ្ញា សូ ឡេងធីតា កញ្ញា វុធ វិជ្ជរ៉ា

លោក អ៊ុក សុវណ្ណឫទ្ធិ លោក សុភាព ដារ៉ាវីន


### គាំទ្រដោយ៖


ELBBL English Language Based Bachelor of Law Program — RAOUL WALLENBERG INSTITUTE — ស៊ុយអែត Sverige — LAW CLINIC RULE - English Language Based Bachelor of Law (ELBBL) Program

ឯកសារខាងលើនេះ គឺជាតម្រូវការមួយសម្រាប់ការបញ្ចប់វគ្គជំនាញវិជ្ជាជីវៈច្បាប់ (Professional Legal Skills) នៃកម្មវិធីសិក្សានីតិសាស្ត្រជាភាសាអង់គ្លេស (ELBBL) របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) ដែលបានបង្កើតឡើងក្នុងគោលបំណងអប់រំ និងចែករំលែកចំណេះដឹងផ្នែកច្បាប់តែប៉ុណ្ណោះ។ ពួកយើងស្វាគមន៍ក្នុងការទទួលនូវមតិសម្រាប់ធ្វើការកែលម្អ។